# សេចក្តីថ្លែងការណ៍

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រារព្ធកម្មវិធីរម្លឹកខួបប្រាំបីឆ្នាំនៃមរណភាព

# លោកបណ្ឌិត កែម ឡី

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») នឹងប្រារព្ធកម្មវិធីរម្លឹកខួបប្រាំបីឆ្នាំនៃមរណភាពលោកបណ្ឌិត កែម ឡី ជាអ្នកវិភាគនយោបាយដ៏ល្បីល្បាញ និងសកម្មក្នុងការតស៊ូមតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា។ លោកបណ្ឌិត កែម ឡី ធ្លាប់ជាសមាជិកក្រុមប្រឹក្សាភិបាលនៃ ម.ស.ម.ក ចាប់ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៤ ផងដែរ។ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់យ៉ាងអាណោចអាធ័មទាំងកណ្តាលថ្ងៃនៅស្ថានីយប្រេងឥន្ធនៈមួយកន្លែងក្នុងរាជធានីភ្នំពេញ។ ក្នុងការប្រារព្ធកម្មវិធីរម្លឹកខួបប្រាំបីឆ្នាំនៃមរណភាពលោកបណ្ឌិត ម.ស.ម.ក នឹងអនុវត្តសកម្មភាពមួយចំនួននៅក្នុងខែកក្កដា ដូចខាងក្រោម៖

- ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែកក្កដា ម.ស.ម.ក នឹងប្តូរគម្របទំព័រហ្វេសប៊ុក ដោយដាក់តាំងជំនួសវិញនូវរូបថតរបស់លោកបណ្ឌិត កែម ឡី ។
- ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០៤ ខែកក្កដា នឹងចេញសេចក្តីអញ្ជើញសាធារណជនឱ្យចូលរួមសរសេរសារបង្ហាញពីការនឹករឭកចំពោះលោកបណ្ឌិត កែម ឡី ។
- នៅថ្ងៃទី០២ ខែកក្កដា នឹងបង្ហោះសម្រង់សម្តីសំខាន់ៗរបស់លោកបណ្ឌិត កែម ឡី នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។
- នៅថ្ងៃទី០៥ ខែកក្កដា នឹងរៀបចំកម្មវិធីវិទ្យុពិភាក្សាផ្សាយទៅលើប្រធានបទស្តីពី «ការរម្លឹកខួបប្រាំបីឆ្នាំនៃមរណភាពលោកបណ្ឌិត កែម ឡី» ដែលមានផ្សាយផ្ទាល់នៅលើទំព័រហ្វេសប៊ុក។
- នៅថ្ងៃទី០៩ ខែកក្កដា នឹងរៀបចំកម្មវិធីរម្លឹកខួបប្រាំបីឆ្នាំនៃមរណភាពលោកបណ្ឌិត កែម ឡី នៅការិយាល័យ ម.ស.ម.ក ។
- នៅថ្ងៃទី១១ ខែកក្កដា នឹងបង្ហោះវីដេអូចំណងជើងថា «៨ ឆ្នាំ នៃការចងចាំ» នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។
- ពីថ្ងៃទី១៥ ដល់ទី៣១ ខែកក្កដា នឹងមានបង្ហោះសម្រង់សម្តីរបស់លោកបណ្ឌិត កែម ឡី ជាប្រភេទវីដេអូសំឡេង នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក លោក រស់ សារ៉ាត់ អ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋាន តាមរយៈអ៊ីម៉ែល** rossarath@cchrcambodia.org **ឬ ទូរស័ព្ទ ០១៧ ៨៨៦ ៦៩៥ ។**

– ចប់ –

**<u>បណ្ណាធិការៈ</u>**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») បង្កើតឡើងក្នុងឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អែស អូ អែស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី៕